ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# ក្របខណ្ឌគន្លងអាជីពគ្រូបង្រៀន

ក្រសួងអប់រំ យុវជន និងកីឡា
ឆ្នាំ ២០១៨

**បុព្វកថា** .......... **1**

**១. ស្ថានភាពទូទៅ** .......... **1**

១.១ សេចក្តីផ្តើម .......... 1

១.២ ស្ថានភាពអប់រំនៅកម្ពុជា .......... 2

១.៣ ចក្ខុវិស័យ .......... 4

១.៤ គោលបំណង និងគោលដៅ .......... 4

១.៤.១ គោលបំណង .......... 4

១.៤.២ គោលដៅ .......... 4

១.៥ វិសាលភាព .......... 4

**២. គន្លងអាជីពគ្រូបង្រៀន** .......... **5**

២.១ អាជីពគ្រូបង្រៀន .......... 5

២.១.១ គន្លងគ្រូបង្រៀន .......... 5

២.១.២ គន្លងគណៈគ្រប់គ្រងសាលារៀន .......... 5

២.១.៣ គន្លងអ្នកឯកទេស .......... 6

២.២ លក្ខណវិនិច្ឆ័យ .......... 6

២.៣ ភាពបត់បែននៃគន្លងអាជីពគ្រូបង្រៀន .......... 8

**៣. ផែនការសកម្មភាព** .......... **8**

៣១. យន្តការអនុវត្ត .......... 8

៣២. លិខិតបទដ្ឋានគតិយុត្ត .......... 8

៣៣. ប្រព័ន្ធលើកទឹកចិត្ត .......... 9

៣ ៤. ប្រព័ន្ធអភិវឌ្ឍន៍អាជីព .......... 9

៣៥. ប្រព័ន្ធវាយតម្លៃគុណផល .......... 9

៣៦. ផែនការសកម្មភាពអនុវត្តលម្អិត .......... 10

**៤. សន្និដ្ឋាន** .......... **15**

**សន្ទានុក្រម** .......... **16**

# បុព្វកថា

រាជរដ្ឋាភិបាលកម្ពុជា មានចក្ខុវិស័យប្រែក្លាយកម្ពុជាឱ្យទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងចំណូលខ្ពស់នៅឆ្នាំ២០៥០។ ការធានាសម្រេចចក្ខុវិស័យនេះ ទាមទារឱ្យមានកម្លាំងពលកម្មប្រកបដោយគុណសម្បទាកម្រិតខ្ពស់ រួមមានវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទាដែលឆ្លើយតបទៅនឹងទីផ្សារការងារក្នុងសតវត្សរ៍ទី២១។ គ្រូបង្រៀន គណៈគ្រប់គ្រងសាលារៀន និងអ្នកឯកទេសអប់រំ ជាកម្លាំងចលករជួរមុខ មិនអាចខ្វះបាន ក្នុងការផលិតមូលធនមនុស្សដែលជាកម្លាំងពលកម្មសកម្ម និងមានផលិតភាពសេដ្ឋកិច្ចខ្ពស់ សម្រាប់ធានាកំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍប្រកបដោយចីរភាព។

ប៉ុន្មានឆ្នាំចុងក្រោយនេះ ក្រសួងអប់រំ យុវជន និងកីឡា បានអនុម័តគោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តសម្រាប់អភិវឌ្ឍគ្រូបង្រៀន លើកកម្ពស់គុណភាពអប់រំ និងគុណតម្លៃគ្រូបង្រៀន ដូចជាគោលនយោបាយស្តីពីគ្រូបង្រៀន ផែនការសកម្មភាពអនុវត្តគោលនយោបាយស្តីពីគ្រូបង្រៀន ស្តង់ដានាយកសាលារៀន ស្តង់ដាគ្រឹះស្ថានអប់រំគ្រូបង្រៀន គោលនយោបាយស្តីពីការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំសម្រាប់បុគ្គលិកអប់រំ ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន កម្មវិធីពន្លឿនឆ្ពោះទៅបរិញ្ញាបត្រដល់គ្រូបង្រៀន (១២+២) និងប្រែក្លាយមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ និងសាលាគរុកោសល្យ និងវិក្រឹតការរាជធានីភ្នំពេញ និងខេត្តបាត់ដំបង ឱ្យទៅជាវិទ្យាស្ថានគរុកោសល្យសម្រាប់ផ្តល់ការបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតបរិញ្ញាបត្រ ស្របតាមស្តង់ដាអន្តរជាតិ។

ការស្រាវជ្រាវជាសកលបញ្ជាក់ថា កំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍរបស់ជាតិមួយ គឺពឹងផ្អែកជាចម្បងលើគុណភាពនៃកម្មវិធីសិក្សា និងគ្រូបង្រៀន។ ដូច្នេះ ជោគជ័យនៃការធានាឱ្យមានកំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍប្រកបដោយចីរភាព ត្រូវផ្សាភ្ជាប់ជាមួយនឹងការអភិវឌ្ឍវិជ្ជាជីវៈ អាជីព និងការលើកទឹកចិត្តដល់គ្រូបង្រៀន គណៈគ្រប់គ្រងសាលារៀន និងអ្នកឯកទេសអប់រំ។ ក្របខណ្ឌគន្លងអាជីពគ្រូបង្រៀនជាឯកសារគតិយុត្តដែលគ្រប់ភាគីពាក់ព័ន្ធត្រូវចូលរួម ដើម្បីអភិវឌ្ឍគុណតម្លៃរបស់គ្រូបង្រៀន គណៈគ្រប់គ្រងសាលារៀន និងអ្នកឯកទេសអប់រំ។ ក្នុងក្របខណ្ឌគោលនយោបាយស្តីពីគ្រូបង្រៀន និងផែនការសកម្មភាពអនុវត្តគោលនយោបាយស្តីពីគ្រូបង្រៀន តម្រូវឱ្យរៀបចំបង្កើតក្របខណ្ឌគន្លងអាជីពគ្រូបង្រៀន ក្នុងគោលដៅទាក់ទាញ និងលើកទឹកចិត្តពលរដ្ឋពូកែៗឱ្យចាប់យកអាជីពគ្រូបង្រៀន និងរក្សាគ្រូបង្រៀនល្អ នាយកល្អ និងអ្នកឯកទេសអប់រំពូកែៗ បម្រើការងារក្នុងប្រព័ន្ធអប់រំ។

ក្រសួងអប់រំ យុវជន និងកីឡា សង្ឃឹមយ៉ាងមុតមាំថា ភាគីពាក់ព័ន្ធទាំងអស់នឹងចូលរួមអនុវត្តក្របខណ្ឌគន្លងអាជីពគ្រូបង្រៀននេះដើម្បីជាប្រយោជន៍ដល់ការអភិវឌ្ឍប្រកបដោយចីរភាព។

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ ជួន ណារ៉ុន**

# ១. ស្ថានភាពទូទៅ

## ១.១ សេចក្ដីផ្ដើម

រាជរដ្ឋាភិបាលកម្ពុជា បានដាក់ចេញនូវចក្ខុវិស័យ "ប្រែក្លាយកម្ពុជាឱ្យទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០ ដោយកសាងជាជំហាននូវសង្គមកម្ពុជាមួយដែលមានសុខសន្តិភាព ស្ថិរភាព សណ្ដាប់ធ្នាប់ គោរពគោលការណ៍ប្រជាធិបតេយ្យ នីតិរដ្ឋ សិទ្ធិមនុស្ស និងសេចក្ដីថ្លៃថ្នូររបស់មនុស្ស មានការអភិវឌ្ឍប្រកបដោយចីរភាព មានកោសិកាផ្សារភ្ជាប់គ្នា មានប្រជាជនប្រកបដោយចំណេះដឹងខ្ពស់ និងវប្បធម៌ជ្រៅជ្រះ មានជីវភាពសមរម្យប្រកបដោយសុខដុមរមនាក្នុងសង្គមជាតិ សង្គមគ្រួសារ និងមានកិត្យានុភាពខ្ពស់លើឆាកអន្តរជាតិ"។ ការសម្រេចចក្ខុវិស័យនេះ សេដ្ឋកិច្ចកម្ពុជាត្រូវពឹងផ្អែកយ៉ាងខ្លាំងលើឧស្សាហកម្ម ឬ សេដ្ឋកិច្ចសង្គមពុទ្ធិ។ ដូច្នេះ វិស័យអប់រំដើរតួនាទីសំខាន់បំផុតដើម្បីធានាថា កម្ពុជាមានមូលធនមនុស្សគ្រប់គ្រាន់ និងប្រកបដោយគុណភាពដើម្បីបម្រើការអភិវឌ្ឍជាតិ។

រដ្ឋធម្មនុញ្ញមាត្រា៦៥ ចែងថា "រដ្ឋត្រូវការពារ និងលើកស្ទួយសិទ្ធិរបស់ប្រជាពលរដ្ឋក្នុងការទទួលការអប់រំប្រកបដោយគុណភាពនៅគ្រប់កម្រិត និងត្រូវចាត់វិធានការគ្រប់បែបយ៉ាងជាជំហានៗ ដើម្បីឱ្យការអប់រំបានទៅដល់ប្រជាពលរដ្ឋគ្រប់រូប"។ ឆ្លើយតបតាមរដ្ឋធម្មនុញ្ញ រាជរដ្ឋាភិបាលបានបង្កើតច្បាប់ស្ដីពីការអប់រំ ដែលក្នុងច្បាប់នេះ បានយកចិត្តទុកដាក់ជាពិសេសចំពោះគ្រូបង្រៀនដូចបានចែងក្នុងវាក្យខណ្ឌទី១ និងទី២ នៃមាត្រា៣៧ ថា "បុគ្គលិកអប់រំមានសិទ្ធិទទួលបានតម្លៃវិជ្ជាជីវៈ សេចក្ដីថ្លៃថ្នូរ និងការយកចិត្តទុកដាក់ខ្ពស់ពីសង្គម និងមានសិទ្ធិអភិវឌ្ឍន៍ខាងវិជ្ជាជីវៈ"។

ផ្អែកតាមច្បាប់ស្ដីពីការអប់រំ ក្រសួងអប់រំ យុវជន និងកីឡាបានបង្កើតគោលនយោបាយស្ដីពីគ្រូបង្រៀន និងក្របខណ្ឌគតិយុត្តផ្សេងៗដើម្បីធានាថា បុគ្គលិកអប់រំទទួលបានសិទ្ធិ និងបំពេញកាតព្វកិច្ចរបស់ខ្លួនដូចចែងក្នុងច្បាប់ស្ដីពីការអប់រំ។ គោលនយោបាយស្ដីពីគ្រូបង្រៀន មានចក្ខុវិស័យកសាងគ្រូបង្រៀនឱ្យមានចំណេះដឹង ជំនាញ សីលធម៌ និងមានសមត្ថភាពអនុវត្តវិជ្ជាជីវៈដោយមានការទទួលស្គាល់ពីសង្គម។ ដើម្បីអនុវត្តគោលនយោបាយស្ដីពីគ្រូបង្រៀន ក្រសួងអប់រំ យុវជន និងកីឡា បានបង្កើតផែនការសកម្មភាពអនុវត្តគោលនយោបាយគ្រូបង្រៀន ដែលបានចង្អុលបង្ហាញអំពីការរៀបចំគន្លងអាជីពគ្រូបង្រៀនក្នុងយុទ្ធសាស្ត្រទី២។

វិស័យអប់រំជាមូលដ្ឋានគ្រឹះសម្រាប់អភិវឌ្ឍជាតិ។ គ្រូបង្រៀនត្រូវបានចាត់ទុកជាសសរស្ដម្ភក្នុងវិស័យអប់រំ។ ប៉ុន្តែក្នុងក្របខណ្ឌមន្ត្រីសាធារណៈទាំងក្នុងប្រទេសអភិវឌ្ឍន៍ និងប្រទេសកំពុងអភិវឌ្ឍន៍ ជាទូទៅគ្រូបង្រៀនមិនសូវមានឱកាសអភិវឌ្ឍវិជ្ជាជីវៈ និងគ្មានតំណែងបន្តខ្ពស់ជាងនេះទេ ពោលគឺមានងារជាគ្រូបង្រៀនពេញមួយជីវិត។ ប្រការនេះ

នាំឱ្យមានការបង្កើតគន្លងអាជីពគ្រូបង្រៀននៅជុំវិញពិភពលោក ដូចជាសហរដ្ឋអាមេរិក អូស្ត្រាលី ជប៉ុន កូរ៉េ និងសិង្ហបុរីជាដើម។ ប្រទេសទាំងនោះ បានប្រើគន្លងអាជីពគ្រូបង្រៀន ដើម្បីពង្រឹងគុណភាពអប់រំ ពោលគឺការបង្រៀន និងការរៀន។ ប្រទេសអូស្ត្រាលីបានប្រើគន្លងអាជីពគ្រូបង្រៀន ដើម្បីពង្រាយគ្រូបង្រៀនឱ្យទៅបង្រៀននៅតំបន់ដាច់ស្រយាល ចំណែកនៅប្រទេសកូរ៉េ គន្លងអាជីពគ្រូបង្រៀនជាឧបករណ៍ពង្រាយគ្រូនៅតំបន់ជួបការលំបាក ដំឡើងលាភការ និងជាបុរេលក្ខខណ្ឌដើម្បីគ្រូបង្រៀនមានឱកាសក្លាយជានាយករង នាយក ឬអ្នកឯកទេសអប់រំនៅតាមសាលារៀន។

ប្រទេសនីមួយៗមានយន្តការអនុវត្តគន្លងអាជីពគ្រូបង្រៀនផ្សេងៗគ្នា ប៉ុន្តែយន្តការទាំងអស់មានគោលដៅតែមួយ គឺដើម្បីអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈគ្រូបង្រៀនក្នុងគន្លងអាជីព។ ជាក់ស្តែង ចាប់ពីពេលអនុវត្តគន្លងអាជីពគ្រូបង្រៀននៅប្រទេសថៃក្នុងឆ្នាំ២០០០ មានបុគ្គលិកអប់រំជាច្រើន ជាពិសេសគ្រូបង្រៀនបានទៅទទួលវគ្គវិក្រឹតការតាមតម្រូវការរបស់សាលារៀន ដើម្បីសន្សំក្រេឌីត និងទទួលបានឋានៈវិជ្ជាជីវៈថ្មី។ នៅប្រទេសថៃ គន្លងអាជីពគ្រូបង្រៀន បែងចែកឋានៈវិជ្ជាជីវៈគ្រូបង្រៀនជាបួនកម្រិត គឺ គ្រូអាជីព គ្រូអាជីពជាន់ខ្ពស់ អ្នកឯកទេស និងអ្នកឯកទេសជាន់ខ្ពស់។ ចំណែកប្រទេសឡាវ គន្លងអាជីពគ្រូបង្រៀនអនុវត្តតែចំពោះគ្រូបង្រៀនប៉ុណ្ណោះ។

គន្លងអាជីពគ្រូបង្រៀន ត្រូវបានរៀបចំឡើងដោយក្រសួងអប់រំ យុវជន និងកីឡា ផ្អែកតាមនិន្នាការនៃការអនុវត្តគន្លងអាជីពនៅប្រទេសអភិវឌ្ឍ និងក្នុងតំបន់ ក្នុងគោលដៅពង្រឹងគុណភាពបុគ្គលិកអប់រំ ជាពិសេសគ្រូបង្រៀន គណៈគ្រប់គ្រងសាលារៀន និងអ្នកឯកទេសអប់រំ ដើម្បីឆ្លើយតបនឹងការប្រែប្រួលសង្គម និងសេដ្ឋកិច្ចជាតិ និងអន្តរជាតិ និងដោះស្រាយក្នុងវិស័យអប់រំ។

## ១.២ ស្ថានភាពអប់រំនៅកម្ពុជា

ការអប់រំរបស់កម្ពុជាមានការរីកចម្រើនខាងបរិមាណ ជាពិសេសនៅបឋមសិក្សា ប៉ុន្តែនៅមធ្យមសិក្សាវិញ ទាំងបរិមាណ និងគុណភាពនៅតែមានបញ្ហា ដែលបណ្តាលមកពីកត្តាជាច្រើន ជាពិសេសខ្វះគ្រូបង្រៀន អ្នកគ្រប់គ្រងសាលារៀន និងអ្នកឯកទេសអប់រំនៅតំបន់ជួបការលំបាក។

កម្ពុជានៅតែប្រឈមនឹងការពង្រឹងគុណភាពគ្រូបង្រៀន រក្សាគ្រូបង្រៀននៅបម្រើការងារក្នុងមុខងារអប់រំបានយូរ ឬរហូតដល់ចូលនិវត្តន៍ ទាក់ទាញអ្នកមានឧបនិស្ស័យ ជាពិសេស សិស្សដែលមាននិទ្ទេសល្អៗចូលបម្រើការងារជាគ្រូបង្រៀនក្នុងវិស័យអប់រំ។ ជាមធ្យម ក្រសួងអប់រំ យុវជន និងកីឡាបាត់បង់បុគ្គលិកអប់រំប្រមាណជាង២០០០នាក់ក្នុងមួយឆ្នាំ ដែលក្នុងនោះអ្នកចូលនិវត្តន៍មានប្រមាណ ១៥០០នាក់ លុបឈ្មោះចោលពីក្របខណ្ឌចំនួន៥០០នាក់ និងសុំផ្ទេរទៅក្រសួងផ្សេងៗ មានចំនួន ២០០នាក់។ កត្តាបាត់បង់

បុគ្គលិកអប់រំ និងកត្តាខ្វះសិស្សពូកែៗមកចូលបម្រើក្នុងវិស័យអប់រំ ជាកង្វល់របស់សាធារណៈ របស់ក្រសួងអប់រំ យុវជន និងកីឡា និងរដ្ឋាភិបាល។

ការស្រាវជ្រាវជាច្រើនពន្យល់ថា គ្រូបង្រៀនមានសញ្ញាបត្រកាន់តែខ្ពស់ ការបង្រៀនកាន់តែមានគុណភាពខ្ពស់។ ប្រទេសក្នុងតំបន់អាស៊ីអាគ្នេយ៍ភាគច្រើន គ្រូបង្រៀនត្រូវមានសញ្ញាបត្របរិញ្ញាបត្រ+២។ ចំណែកនៅកម្ពុជា គ្រូបង្រៀនភាគច្រើនមិនទាន់មានបរិញ្ញាបត្រនៅឡើយ ទោះបីជាការបណ្តុះបណ្តាលគ្រូបង្រៀនមានការវិវត្តន៍ជាច្រើនក៏ដោយ។ គ្រូបង្រៀនមួយចំនួនដែលចូលក្នុងក្របខណ្ឌអប់រំកាលពីឆ្នាំ១៩៩២-១៩៩៣ មានសញ្ញាបត្រ ៨+១ (បង្រៀននៅថ្នាក់មត្តេយ្យ) ៨+២ (បង្រៀននៅកម្រិតបឋមសិក្សា) ១១+២ (ថ្នាក់មធ្យមសិក្សាបឋមភូមិ) ១០+៤ និងបរិញ្ញាបត្រ (ថ្នាក់មធ្យមសិក្សាទុតិយភូមិ)។ ក្នុងឆ្នាំ២០១៦-១៧ ការបណ្តុះបណ្តាលគ្រូបង្រៀនអនុវត្តប្រព័ន្ធ ១២+២ទាំងអស់សម្រាប់គ្រប់កម្រិតសិក្សា លើកលែងតែកម្រិតមធ្យមសិក្សាទុតិយភូមិដែលអនុវត្តប្រព័ន្ធបរិញ្ញាបត្រ+១។ ដើម្បីឆ្លើយតបនឹងការរៀន និងបង្រៀន ក្នុងសម័យបច្ចេកវិទ្យាទំនើប កម្ពុជាត្រូវការគ្រូបង្រៀនគ្រប់កម្រិតមានសញ្ញាបត្រយ៉ាងហោចណាស់បរិញ្ញាបត្រ ដើម្បីបង្រៀនចាប់ពីមត្តេយ្យសាលារហូតដល់មធ្យមសិក្សាទុតិយភូមិ។

ក្រៅពីការខ្វះគ្រូដែលមានគុណសម្បទា សាលារៀនមួយចំនួនមានខ្វះ ឬលើសគ្រូបង្រៀន ឬយ៉ាងហោចណាស់មានបញ្ហាលើស ឬខ្វះតាមគ្រូបង្រៀនតាមមុខវិជ្ជា ឬមានចំនួនសិស្សច្រើនពេកក្នុងមួយថ្នាក់ៗ។ ជាទូទៅ ក្រសួងអប់រំ យុវជន និងកីឡា ខ្វះគ្រូបង្រៀនគ្រប់ខេត្ត ពិសេស កម្រិតបឋមសិក្សាដូចជានៅខេត្តសៀមរាប កណ្តាល កំពង់ចាម និងត្បូងឃ្មុំ។ ទន្ទឹមគ្នានេះដែរ មានខេត្តមួយចំនួនដែលមានគ្រូលើសជាពិសេសក្នុងរាជធានីភ្នំពេញ។ កត្តាមួយក្នុងចំណោមកត្តាលើស ឬខ្វះគ្រូបង្រៀន គឺកង្វះការលើកទឹកចិត្តឱ្យគ្រូបង្រៀនទៅបំពេញភារកិច្ចនៅកន្លែងដែលខ្វះខាត។ គន្លងអាជីពគ្រូបង្រៀនជាឧបករណ៍គតិយុត្តផ្តល់ការលើកទឹកចិត្តបន្ថែមចំពោះគ្រូបង្រៀន ដែលនៅកន្លែងលើសគ្រូបង្រៀន ឱ្យទៅបម្រើការងារនៅសាលារៀនដែលខ្វះគ្រូ។

គ្រូបង្រៀនជាមូលដ្ឋានគ្រឹះក្នុងការលើកកម្ពស់គុណភាពអប់រំ។ គុណសម្បទារបស់គ្រូបង្រៀនដើម្បីធានាប្រសិទ្ធភាពការងារ ដែលមានចែងក្នុងស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀនរួមបញ្ចូលទាំងចំណេះដឹងវិជ្ជាជីវៈ ការប្រតិបត្តិវិជ្ជាជីវៈ ការសិក្សាវិជ្ជាជីវៈ និងសីលធម៌វិជ្ជាជីវៈ។ ទោះបីជាយ៉ាងនេះក្តី គ្រូបង្រៀននៅតែមិនអាចបំពេញកិច្ចការរបស់ខ្លួនប្រកបដោយប្រសិទ្ធភាពនោះទេ ពីព្រោះថា លទ្ធផលប្រឡងបង្ហាញថា ថ្នាក់ទី៣ ឆ្នាំសិក្សា ២០១៦ និងថ្នាក់ទី៦ ឆ្នាំសិក្សា ២០១៥ ឃើញថា សិស្សប្រមាណជា ៥០% គ្មានកម្រិតចំណេះដឹងគ្រប់គ្រាន់ក្នុងមុខវិជ្ជាគណិតវិជ្ជា និងភាសាខ្មែរ ដូចដែលបានរំពឹងទុកក្នុងក្របខណ្ឌកម្មវិធីសិក្សាសម្រាប់កម្រិតសិក្សានីមួយៗ។

ក្នុងដំណើរឆ្ពោះទៅសង្គមពុទ្ធិ បដិវត្តន៍ឧស្សាកម្មទី៤ និងពលរដ្ឋសកល កម្ពុជាត្រូវពង្រឹងវិស័យអប់រំដើម្បីឱ្យពលរដ្ឋរបស់ខ្លួន ដែលឆ្លងកាត់ប្រព័ន្ធអប់រំ មានកញ្ចប់សមត្ថភាព នៃសតវត្សរ៍ទី២១ ដូចជា បំណិនត្រិះរិះពិចារណា ដោះស្រាយបញ្ហា ការងារក្រុម ប្រាស្រ័យទាក់ទង ប្រើប្រាស់បច្ចេកវិទ្យាព័តមាន និងការរស់នៅចម្រុះវប្បធម៌ និងជាតិសាសន៍ ។ល។ គ្រូបង្រៀនត្រូវត្រៀមខ្លួនដើម្បីឆ្លើយតបនឹងតម្រូវការរបស់សិស្ស។ តាមទិន្នន័យកន្លងមក គ្រូបង្រៀន នាយកសាលារៀន ឬ អ្នកឯកទេសអប់រំ នៅខ្វះខាតបំណិនទាំងនេះ ដែលក្រសួងអប់រំ យុវជន និងកីឡាកំពុងតែព្យាយាមឆ្លើយតបតាមគ្រប់រូបភាព និងគ្រប់មធ្យោបាយ។

## ១.៣ ចក្ខុវិស័យ

ក្របខណ្ឌគន្លងអាជីពគ្រូបង្រៀនមានចក្ខុវិស័យកសាងគ្រូបង្រៀន អ្នកគ្រប់គ្រងសាលារៀន និងអ្នកឯកទេសអប់រំ ឱ្យមានចំណេះដឹង ជំនាញ សីលធម៌ និងមានសមត្ថភាពវិជ្ជាជីវៈ ដោយមានការទទួលស្គាល់ពីសង្គម។

## ១.៤ គោលបំណង និងគោលដៅ

### ១.៤ ១.គោលបំណង

ក្របខណ្ឌនេះមានគោលបំណងទាក់ទាញ អភិវឌ្ឍ គាំទ្រ និងលើកទឹកចិត្ត ដើម្បីរក្សាគ្រូបង្រៀន អ្នកគ្រប់គ្រងសាលារៀន និងអ្នកឯកទេសអប់រំ ឱ្យប្រើការងារក្នុងប្រព័ន្ធអប់រំ។

### ១.៤.២ គោលដៅ

ក្របខណ្ឌនេះ មានគោលដៅ ៖

- អភិវឌ្ឍគន្លងគ្រូបង្រៀន គន្លងគណៈគ្រប់គ្រងសាលារៀន និងគន្លងអ្នកឯកទេសអប់រំ
- កំណត់លក្ខណវិនិច្ឆ័យ និងសូចនាករគុណផលការងារនៅកម្រិតនីមួយៗ នៃគន្លងអាជីពទាំងបី
- បង្កើតយន្តការអនុវត្ត និងវាយតម្លៃជាប្រព័ន្ធ ដើម្បីទាក់ទាញ អភិវឌ្ឍ គាំទ្រ និងលើកទឹកចិត្តគ្រូបង្រៀន

## ១.៥ វិសាលភាព

ក្របខណ្ឌនេះ មានវិសាលភាពអនុវត្តចំពោះគ្រូបង្រៀន គណៈគ្រប់គ្រងសាលារៀន និងអ្នកឯកទេសអប់រំ ក្នុងក្របខណ្ឌក្រសួងអប់រំ យុវជន និងកីឡា។

## ២. គន្លងអាជីពគ្រូបង្រៀន

គន្លងអាជីពគ្រូបង្រៀន ជាប្រព័ន្ធលើកទឹកចិត្តគ្រូបង្រៀន គណៈគ្រប់គ្រងសាលារៀន និងអ្នកឯកទេសអប់រំ។

### ២.១ អាជីពគ្រូបង្រៀន

អាជីពគ្រូបង្រៀនចែកចេញជាបីគន្លង ១) គន្លងគ្រូបង្រៀន ២) គន្លងគណៈគ្រប់គ្រងសាលារៀន និង ៣) គន្លងអ្នកឯកទេសអប់រំ។

#### ២.១.១ គន្លងគ្រូបង្រៀន

គន្លងគ្រូបង្រៀនត្រូវបានរៀបចំសម្រាប់គ្រូបង្រៀនដែលមានឧបនិស្ស័យបង្រៀនសិស្សក្នុងថ្នាក់រៀន និងចែកចេញជាបីកម្រិត ៖

១) គ្រូឈានមុខ

គ្រូឈានមុខមានគុណផលការងាធ្វើឱ្យប្រសើរឡើងនូវការអនុវត្តកម្មវិធីសិក្សា ការបង្រៀន ការវាយតម្លៃ និងគុណផលសិក្សារបស់សិស្សនៅកម្រិតសាលារៀន។

២) គ្រូគំរូ

គ្រូគំរូមានគុណផលការងារធ្វើឱ្យប្រសើរឡើងនូវការអនុវត្តកម្មវិធីសិក្សា ការបង្រៀន ការវាយតម្លៃ និងគុណផលសិក្សារបស់សិស្ស នៅតាមសាលារៀន កម្រិតស្រុក ឬខេត្ត។

៣) គ្រូឆ្នើម

គ្រូឆ្នើមមានគុណផលការងារធ្វើប្រសើរឡើងដល់គោលនយោបាយ និងអន្តរាគមន៍ពាក់ព័ន្ធនឹងការអនុវត្តកម្មវិធីសិក្សា ការបង្រៀន ការវាយតម្លៃ គុណផលសិក្សារបស់សិស្ស និងគុណផលសាលារៀន នៅកម្រិតជាតិ។

#### ២.១.២ គន្លងគណៈគ្រប់គ្រងសាលារៀន

គន្លងគណៈគ្រប់គ្រងសាលារៀនត្រូវបានរៀបចំសម្រាប់នាយក និងនាយករងដែលមានឧបនិស្ស័យដឹកនាំ និងគ្រប់គ្រងសាលារៀន និងចែកចេញជាបីកម្រិត ៖

១) នាយកឈានមុខ

នាយកឈានមុខមានគុណផលដឹកនាំ និងគ្រប់គ្រងសាលារៀន ធ្វើឱ្យប្រសើរឡើងនូវគុណផលសិក្សារបស់សិស្ស តាមរយៈការគ្រប់គ្រងលើការអនុវត្តកម្មវិធីសិក្សា ការបង្រៀន ការវាយតម្លៃលទ្ធផលសិក្សា និងការអភិវឌ្ឍវិជ្ជាជីវៈបង្រៀនជាប្រចាំ នៅកម្រិតសាលារៀន។

២) នាយកគំរូ

នាយកគំរូមានគុណផលដឹកនាំ និងគ្រប់គ្រងសាលារៀន ធ្វើឱ្យប្រសើរឡើងនូវការអនុវត្តកម្មវិធីសិក្សា ការបង្រៀន ការវាយតម្លៃលទ្ធផលសិក្សា និងការអភិវឌ្ឍវិជ្ជាជីវៈបង្រៀនជាប្រចាំ នៅកម្រិតស្រុក ឬខេត្ត។

៣) នាយកឆ្នើម

នាយកឆ្នើមមានគុណផលដឹកនាំ និងគ្រប់គ្រងសាលារៀន ធ្វើឱ្យប្រសើរឡើងដល់គោលនយោបាយ និងការអនុវត្តពាក់ព័ន្ធនឹងការអនុវត្តកម្មវិធីសិក្សា ការបង្រៀន ការវាយតម្លៃលទ្ធផលសិក្សា និងការអភិវឌ្ឍវិជ្ជាជីវៈបង្រៀនជាប្រចាំ នៅកម្រិតជាតិ។

២.១.៣ គន្លងអ្នកឯកទេស

គន្លងអ្នកឯកទេសត្រូវបានរៀបចំសម្រាប់អ្នកជំនាញបម្រើការក្នុងប្រព័ន្ធអប់រំ ដែលមានឧបនិស្ស័យស្រាវជ្រាវ សរសេរសៀវភៅ និងតាក់តែងគោលនយោបាយ ហើយចែកចេញជាបីកម្រិត ៖

១) អ្នកឯកទេសឈានមុខ

អ្នកឯកទេសឈានមុខមានគុណផលការងារ ធ្វើឱ្យប្រសើរឡើងនូវគុណផលសិក្សារបស់សិស្ស តាមរយៈការស្រាវជ្រាវ និងការផ្តល់យោបល់ជាសំណោរ លើការអនុវត្តកម្មវិធីសិក្សា វិធីសាស្ត្រគរុកោសល្យ ការវាយតម្លៃ ប្រឹក្សាយោបល់ អធិការកិច្ច ធានាគុណភាព និងការអភិវឌ្ឍវិជ្ជាជីវៈបង្រៀន នៅកម្រិតសាលារៀន។

២) អ្នកឯកទេសគំរូ

អ្នកឯកទេសគំរូមានគុណផលការងារធ្វើឱ្យប្រសើរឡើងនូវគុណផលសិក្សារបស់សិស្ស តាមរយៈការស្រាវជ្រាវ និងការផ្តល់យោបល់ជាសំណោរលើការអនុវត្តកម្មវិធីសិក្សា វិធីសាស្ត្រគរុកោសល្យ ការវាយតម្លៃ ប្រឹក្សាយោបល់ អធិការកិច្ច ធានាគុណភាព និងការអភិវឌ្ឍវិជ្ជាជីវៈបង្រៀន នៅកម្រិតស្រុក ឬខេត្ត។

៣) អ្នកឯកទេសឆ្នើម

អ្នកឯកទេសឆ្នើមមានគុណផលការងារធ្វើឱ្យប្រសើរឡើងដល់គោលនយោបាយ និងការអនុវត្ត ពាក់ព័ន្ធនឹងការស្រាវជ្រាវ និងការផ្តល់យោបល់ជាសំណោរ លើការអនុវត្តកម្មវិធីសិក្សា វិធីសាស្ត្រគរុកោសល្យ ការវាយតម្លៃ ប្រឹក្សាយោបល់ អធិការកិច្ច ធានាគុណភាព និងការអភិវឌ្ឍវិជ្ជាជីវៈបង្រៀន នៅកម្រិតជាតិ។

## ២.២ លក្ខណវិនិច្ឆ័យ

បុគ្គលិកអប់រំដែលមានក្របខណ្ឌគ្រូបង្រៀនកម្រិតបឋម ក្របខណ្ឌគ្រូបង្រៀនកម្រិតមូលដ្ឋាន និងក្របខណ្ឌគ្រូបង្រៀនកម្រិតឧត្តម ដែលកំពុងបម្រើការងារតាមគ្រឹះស្ថានអប់រំសាធារណៈ មានឧបនិស្ស័យសម្រាប់បំពេញលក្ខខណ្ឌចូលក្នុងគន្លងអាជីពគ្រូបង្រៀន។

ការវាយតម្លៃបេក្ខជនដើម្បីចាត់ចូលឋានៈវិជ្ជាជីវៈក្នុងគន្លងនីមួយៗ នៃគន្លងអាជីពគ្រូបង្រៀននេះ ត្រូវប្រើលក្ខណវិនិច្ឆ័យនីមួយៗ ដូចមានពន្យល់ខាងក្រោម។ លក្ខណវិនិច្ឆ័យមានពីរប្រភេទគឺ លក្ខខណ្ឌតម្រូវ និងលក្ខខណ្ឌជម្រើស។ លក្ខខណ្ឌតម្រូវក្នុងគន្លងមួយអាចខុសពីលក្ខខណ្ឌតម្រូវក្នុងគន្លងមួយទៀត។ លក្ខខណ្ឌខ្លះជាលក្ខខណ្ឌតម្រូវក្នុងគន្លងមួយអាចជាលក្ខខណ្ឌជម្រើសក្នុងគន្លងមួយទៀត។ គោលការណ៍ និងនីតិវិធីនៃការវាយតម្លៃបេក្ខជន ដើម្បីចាត់ចូលគន្លងនីមួយៗនៃគន្លងអាជីពគ្រូបង្រៀន ត្រូវកំណត់ក្នុងគោលការណ៍ណែនាំដោយឡែក។

១)	សញ្ញាបត្រ
សំដៅដល់សញ្ញាបត្រខ្ពស់បំផុតដែលបេក្ខជនទទួលបានពីគ្រឹះស្ថានឧត្តមសិក្សា។

២)	អតីតភាពការងារ
សំដៅដល់ចំនួនឆ្នាំ ចំណេះដឹង និងបំណិន ដែលបេក្ខជនទទួលបានពីការបំពេញការងារដោយជោគជ័យ។

៣)	ព្រឹត្តិបត្រវិជ្ជាជីវៈ
សំដៅដល់អត្ថបទស្រាវជ្រាវដែលត្រូវបានចុះផ្សាយក្នុងព្រឹត្តិបត្រវិជ្ជាជីវៈ ដែលមានគណៈកម្មការពិនិត្យ និងវាយតម្លៃអត្ថបទ។

៤)	សម្ភារឧបទេស
សំដៅដល់ឯកសារមេរៀន ឬសម្ភារៈផ្សេងៗដែលបានបង្កើតសម្រាប់ប្រើប្រាស់ដើម្បីធ្វើឱ្យការរៀន និងបង្រៀនកាន់តែមានប្រសិទ្ធភាព និងឆ្លើយតបទៅនឹងតម្រូវការរបស់អ្នកសិក្សា។

៥)	សៀវភៅ
សំដៅដល់សៀវភៅដែលបានសរសេរម្នាក់ឯង ឬសហការជាមួយអ្នកដទៃ និងបានបោះពុម្ព ដោយគ្រឹះស្ថានបោះពុម្ពផ្សាយដែលមានអាជ្ញាបណ្ណ សម្រាប់ប្រើប្រាស់ក្នុងការបង្រៀន ឬជាឯកសារយោងសម្រាប់ការរៀបចំគោលនយោបាយ ឬធ្វើអន្តរាគមន៍លើផ្នែកបរិមាណ និងគុណភាពអប់រំ។

៦)	ឯកសារសោតទស្សន៍
សំដៅដល់ឯកសារដែលបានផលិតជាសំឡេង និង/ឬជាវីដេអូ និងដាក់ឱ្យមានការប្រើប្រាស់ជាទូទៅតាមបណ្តាញអនឡាញ ដូចជា វេបសាយ យូធូប ហ្វេសប៊ុក។ល។

៧)	តេស្តស្តង់ដា
សំដៅដល់កម្រងសំណួរចម្លើយសម្រាប់វាស់លទ្ធផលសិក្សាកម្រិតថ្នាក់រៀន និងមុខវិជ្ជា ដែលត្រូវបានរៀបចំដោយស្ថាប័ន ឬ អង្គភាពមានសមត្ថកិច្ចរបស់ក្រសួងអប់រំ យុវជន និងកីឡា ដើម្បីវាស់វិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទារបស់សិស្សស្របតាមការកំណត់ក្នុងកម្មវិធីសិក្សាតាមមុខវិជ្ជា និងកម្រិតថ្នាក់រៀន។

៨)	ភាសាបរទេស
សំដៅដល់កម្រិតវប្បធម៌ភាសាបរទេស ដែលប្រើប្រាស់ជាប្រចាំសម្រាប់ការស្រាវជ្រាវដើម្បីធ្វើឱ្យប្រសើរនូវគុណផលការងារ។

៩)	បច្ចេកវិទ្យាព័ត៌មាន
សំដៅដល់បំណិនប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានសម្រាប់ការរៀន និងការបង្រៀន ការគ្រប់គ្រង និងការស្រាវជ្រាវ។

១០)	កម្មវិធីអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ
សំដៅដល់ចំនួនកម្មវិធីអភិវឌ្ឍន៍វិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទាដែលបានចូលរួម តាមរយៈការបើកវគ្គបំប៉ន សិក្ខាសាលា ឬវគ្គបណ្តុះបណ្តាល ឬបង្កើតការស្រាវជ្រាវរួមជាមួយគ្រូបង្រៀនដទៃ។

១១) បទពិសោធពិសេស

សំដៅដល់ចំនួនឆ្នាំបំពេញការងារ តាមរយៈការបង្រៀន ការដឹកនាំ និងការស្រាវជ្រាវ និងអភិវឌ្ឍសាលារៀនដែលស្ថិតក្នុងតំបន់ជួបការលំបាកស្របតាមការកំណត់របស់ក្រសួងអប់រំ យុវជន និងកីឡា។

១២) លិខិតគាំទ្រវិជ្ជាជីវៈ

សំដៅដល់ការវាយតម្លៃក្រមសីលធម៌ ដោយសហការី គណៈគ្រប់គ្រងសាលារៀន និងអ្នកពាក់ព័ន្ធផ្សេងទៀត។

១៣) ស្នាដៃ

សំដៅដល់ជ័យលាភីដែលធ្លាប់បានទទួលកន្លងមក ពាក់ព័ន្ធនឹងគុណផលការងារក្នុងការបង្រៀន ដឹកនាំ និងស្រាវជ្រាវលើឯកទេសជាក់លាក់ណាមួយ សំដៅរួមចំណែកដល់ការពង្រីកបរិមាណ និងពង្រឹងគុណភាពអប់រំ។

### ២.៣ ភាពបត់បែននៃគន្លងអាជីពគ្រូបង្រៀន

គ្រូបង្រៀន ឬគណៈគ្រប់គ្រងសាលារៀន ឬអ្នកឯកទេសអប់រំ ក្នុងគន្លងនីមួយៗ អាចជ្រើសរើសគន្លងអាជីពណាមួយ ឬប្តូរពីគន្លងអាជីពមួយទៅគន្លងមួយទៀត នៅពេលគ្រូបង្រៀន ឬគណៈគ្រប់គ្រងសាលារៀន ឬអ្នកឯកទេស បានបំពេញគ្រប់លក្ខខណ្ឌដែលមានចែងក្នុងគន្លងនីមួយៗ។

ការប្តូរមុខតំណែងរបស់គ្រូបង្រៀន គណៈគ្រប់គ្រងសាលារៀន និងអ្នកឯកទេសក្នុងប្រព័ន្ធអប់រំ មិនធ្វើឱ្យគ្រូបង្រៀន គណៈគ្រប់គ្រងសាលារៀន និងអ្នកឯកទេស បាត់បង់ឋានៈវិជ្ជាជីវៈទេ។

## ៣. ផែនការសកម្មភាព

### ៣.១ យន្តការអនុវត្ត

គណៈកម្មការអភិវឌ្ឍន៍គ្រូបង្រៀនមានភារកិច្ចសម្របសម្រួល និងសហការជាមួយភាគីពាក់ព័ន្ធ ដើម្បីរៀបចំយន្តការ ប្រព័ន្ធគាំទ្រ និងនីតិវិធី ព្រមទាំងកៀរគរធនធាន សម្រាប់អនុវត្តក្របខណ្ឌនេះឱ្យទទួលបានជោគជ័យ។

### ៣.២ លិខិតបទដ្ឋានគតិយុត្ត

ដើម្បីអនុវត្តក្របខណ្ឌគន្លងអាជីពគ្រូបង្រៀនឱ្យមានប្រសិទ្ធភាព ត្រូវ៖

- សិក្សាពីផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធដែលមានជាធរមាន
- ធ្វើវិសោធនកម្មលិខិតបទដ្ឋានគតិយុត្តដែលប៉ះពាល់ដល់ការអនុវត្តក្របខណ្ឌគន្លងអាជីពគ្រូបង្រៀន
- រៀបចំលិខិតបទដ្ឋានគតិយុត្តសម្រាប់គាំទ្រដល់ការអនុវត្តក្របខណ្ឌគន្លងអាជីពគ្រូបង្រៀន។ល។

### ៣.៣ ប្រព័ន្ធលើកទឹកចិត្ត

គ្រូបង្រៀនដែលបានបំពេញតាមលក្ខណវិនិច្ឆ័យរបស់ឋានៈវិជ្ជាជីវៈនីមួយៗ នឹងទទួលបានប្រាក់លើកទឹកចិត្តបន្ថែមលើបៀវត្សរ៍ និងអត្ថប្រយោជន៍ផ្សេងៗទៀតដែលត្រូវកំណត់ក្នុងគោលការណ៍ណែនាំដោយឡែក។ ក្រសួងអប់រំ យុវជន និងកីឡា នឹងត្រូវពិភាក្សាជាមួយក្រសួងមុខងារសាធារណៈ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីកំណត់ប្រព័ន្ធលើកទឹកចិត្តនេះ។

ដើម្បីទទួលបានលាភការលើកទឹកចិត្ត គ្រូបង្រៀនត្រូវដាក់កម្រងឯកសារដែលបញ្ជាក់ពីការបំពេញលក្ខណវិនិច្ឆ័យតាមឋានៈវិជ្ជាជីវៈនីមួយៗ ទៅគណៈកម្មការអភិវឌ្ឍន៍គ្រូបង្រៀនសម្រាប់វាយតម្លៃ និងទទួលស្គាល់។

### ៣.៤ ប្រព័ន្ធអភិវឌ្ឍន៍អាជីព

ដើម្បីធានាប្រសិទ្ធភាពក្នុងការអនុវត្តក្របខណ្ឌគន្លងអាជីពគ្រូបង្រៀន ត្រូវ៖

- អនុវត្តគោលនយោបាយស្តីពីការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំសម្រាប់បុគ្គលិកអប់រំ
- អនុវត្តស្តង់ដានាយកសាលារៀន
- បង្កើតប្រព័ន្ធកត់ត្រាការអភិវឌ្ឍវិជ្ជាជីវៈកម្រិតសាលារៀន ថ្នាក់ក្រោមជាតិ និងជាតិ។

### ៣.៥ ប្រព័ន្ធវាយតម្លៃគុណផល

ការវាយតម្លៃគុណផលគ្រូបង្រៀនក្នុងគន្លងអាជីពគ្រូបង្រៀន ត្រូវភ្ជាប់គុណផលរបស់គ្រូបង្រៀន ជាមួយនឹងគុណផលសិក្សារបស់សិស្ស និងគុណផលរបស់សាលារៀន និងការលើកទឹកចិត្តអាជីពដល់គ្រូបង្រៀន គណៈគ្រប់គ្រងសាលារៀន និងអ្នកឯកទេស។ ក្រសួងអប់រំ យុវជន និងកីឡា ត្រូវរៀបចំប្រព័ន្ធវាយតម្លៃក្នុងគន្លងអាជីពគ្រូបង្រៀន។

៣.៦ ផែនការសកម្មភាពអនុវត្តលម្អិត

| សកម្មភាពគោល | | សកម្មភាព | | ក្របខណ្ឌពេលវេលា | ស្ថាប័នទទួលខុសត្រូវ |
|---|---|---|---|---|---|
| **១.** | **ផ្សព្វផ្សាយក្របខណ្ឌគន្លងអាជីពគ្រូបង្រៀន** | ១.១ | បោះពុម្ពក្របខណ្ឌគន្លងអាជីពគ្រូបង្រៀន | ត្រីមាសទី៣ និងទី៤ ២០១៨ | នា.បុគ្គលិក<br>នា.បវ |
| | | ១.២ | រៀបចំសិក្ខាសាលាផ្សព្វផ្សាយក្របខណ្ឌគន្លងអាជីពគ្រូបង្រៀន | ត្រីមាសទី១ និងទី៤ ២០១៩ | នា.បុគ្គលិក<br>នា.បវ |
| | | ១.៣ | បង្កើត App គន្លងអាជីពគ្រូបង្រៀន | ត្រីមាសទី២ និងទី៤ ២០១៩ | នា.បច្ចេកវិទ្យាព័ត៌មាន |
| **២.** | **គោលការណ៍ណែនាំស្តីពីការអនុវត្តក្របខណ្ឌគន្លងអាជីពគ្រូបង្រៀន** | ២.១ | រៀបចំលក្ខណវិនិច្ឆ័យលម្អិតនៃគន្លងនីមួយៗនៃគន្លងអាជីព | ២០១៨ | នា.នីតិកម្ម<br>នា.បុគ្គលិក<br>នា.បវ |
| | | ២.២ | រៀបចំគោលការណ៍ណែនាំស្តីពីការអនុវត្តក្របខណ្ឌគន្លងអាជីពគ្រូបង្រៀន | ត្រីមាសទី២ ២០១៨ | នា.នីតិកម្ម<br>នា. បុគ្គលិក<br>នា.បវ |

| | | | |
|---|---|---|---|
| | ២.៣ ផ្សព្វផ្សាយគោលការណ៍ណែនាំស្តីពីការអនុវត្ត ក្របខណ្ឌគន្លងអាជីពគ្រូបង្រៀន | ២០១៨-២០១៩ | នា. បុគ្គលិក<br>នា.បវ |
| **៣. ការជ្រើសរើសគ្រូបង្រៀន គណៈគ្រប់គ្រងសាលារៀន និងអ្នកឯកទេសអប់រំ** | ៣.១ ការជ្រើសរើសគ្រូបង្រៀនចូលក្នុងគន្លងគ្រូបង្រៀន | ២០២០ | លេខាធិការដ្ឋាន<br>គណៈកម្មការ<br>អភិវឌ្ឍន៍គ្រូបង្រៀន |
| | ៣.២ ការជ្រើសរើសគណៈគ្រប់គ្រងសាលារៀនក្នុងគន្លងគណៈគ្រប់គ្រងសាលរៀន | ២០២១ | លេខាធិការដ្ឋាន<br>គណៈកម្មការ<br>អភិវឌ្ឍន៍គ្រូបង្រៀន |
| | ៣.៣ ការជ្រើសរើសអ្នកឯកទេសក្នុងគន្លងឯកទេស | ២០២១ | លេខាធិការដ្ឋាន<br>គណៈកម្មការ<br>អភិវឌ្ឍន៍គ្រូបង្រៀន |
| **៤. អភិវឌ្ឍវិជ្ជាជីវៈជាប្រចាំសម្រាប់គ្រូបង្រៀន និង គណៈគ្រប់គ្រងសាលារៀន** | ៤.១ បង្កើតក្របខណ្ឌគោលនយោបាយស្តីពីការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំសម្រាប់គ្រូបង្រៀន និងនាយក សាលារៀន | ២០១៨-២០១៩ | នា.បវ |
| | ៤.២ អនុវត្តក្របខណ្ឌគោលនយោបាយស្តីពីការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំសម្រាប់គ្រូបង្រៀន និងនាយកសាលារៀន | រៀងរាល់ឆ្នាំ | នា.បវ |

| | | | | |
|---|---|---|---|---|
| | ៤.៣ | បង្កើតកម្មវិធីអភិវឌ្ឍវិជ្ជាជីវៈនៅវិទ្យាស្ថានគុរុកោសល្យ ឬគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន | ២០១៩ | នា.បវ<br>មជ្ឈមណ្ឌលបណ្តុះបណ្តាលគ្រូបង្រៀន |
| | ៤.៤ | បង្កើតប្រព័ន្ធវិក្រឹតការរៀបចំសម្រាប់វិក្រឹតការគ្រូបង្រៀន ដោយផ្អែកលើអតីតភាពការងារ | ២០១៩ | នា.បវ |
| | ៤.៥ | បង្កើតរចនាសម្ព័ន្ធការងារវិក្រឹតការថ្មីមួយនៅក្នុងគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន | ២០១៩ | នា.បវ |
| | ៤.៦ | អនុវត្តស្តង់ដាគ្រឹះស្ថានអប់រំគ្រូបង្រៀន | រៀងរាល់ឆ្នាំ | នា.បវ<br>គ្រឹះស្ថានអប់រំគ្រូបង្រៀន |
| **៥. ប្រព័ន្ធគាំទ្រគ្រូបង្រៀននៅនឹងកន្លែង** | ៥.១ | អភិវឌ្ឍ និងអនុវត្តយន្តការគាំទ្រគ្រូបង្រៀននៅសាលារៀនដើម្បីពង្រឹងចំណេះដឹងមុខវិជ្ជាឯកទេស និងគរុកោសល្យ | ២០១៩ | នា.បវ<br>គ្រឹះស្ថានសិក្សា |
| | ៥.២ | បង្កើតសមាគមវិជ្ជាជីវៈតាមឯកទេសមុខវិជ្ជា | ២០១៩-២០២០ | នា.នីតិកម្ម |
| | ៥.៣ | បង្កើតក្រុមបច្ចេកទេសក្នុងគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀនដែលបានទទួលស្គាល់សម្រាប់ចុះជួយតាមមុខវិជ្ជា និងបច្ចេកទេសតាមមុខវិជ្ជាឯកទេសឱ្យបានទៀងទាត់ | ២០២០ | |

| | | | |
|---|---|---|---|
| **៦. លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការអនុវត្តក្របខណ្ឌគន្លងអាជីពគ្រូបង្រៀន** | ៦.១ ពិនិត្យឡើងវិញលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការអនុវត្តក្របខណ្ឌគន្លងអាជីពគ្រូបង្រៀន | ត្រីមាសទី៤ ២០១៩ | នា. នីតិកម្ម<br>នា. បុគ្គលិក |
| | ៦.២ បង្កើតលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការអនុវត្តក្របខណ្ឌគន្លងអាជីពគ្រូបង្រៀន | ២០១៩-២០២០ | នា. នីតិកម្ម |
| | ៦.៣ បង្កើតប្រកាសរួមរវាងក្រសួងអប់រំ យុវជន និងកីឡា ក្រសួងមុខងារសាធារណៈ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីប្រព័ន្ធលាភការផ្សាភ្ជាប់នឹងងារវិជ្ជាជីវៈ | ២០១៩-២០២០ | នា.នីតិកម្ម<br>ក្រសួងមុខងារសាធារណៈ<br>ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| **៧. បង្កើតប្រព័ន្ធ និងយន្តការវាយតម្លៃនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ** | ៧.១ បង្កើតប្រព័ន្ធ និងយន្តការវាយតម្លៃគុណផលគ្រូបង្រៀន គណៈគ្រប់គ្រងនាយកសាលារៀននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ | ២០១៩-២០២០ | នា.បវ<br>នា.ធានាគុណភាពអប់រំ |
| | ៧.២ អនុវត្តប្រព័ន្ធ និងយន្តការវាយតម្លៃគុណផលគ្រូបង្រៀន គណៈគ្រប់គ្រងនាយកសាលារៀននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ | ២០១៩-២០២០ | នា.បវ<br>នា.ធានាគុណភាពអប់រំ |

| | | | | |
|---|---|---|---|---|
| ៨. បង្កើតប្រព័ន្ធក្រេឌីតសម្រាប់ផ្តល់ដល់អ្នកដែលបានឆ្លងកាត់វគ្គវិក្រឹតការ | ៨.១ | រៀបចំឱ្យមានឯកភាពគ្នាមួយលើរាល់ប្រភេទនៃវគ្គវិក្រឹតការដើម្បីកំណត់ចំនួនក្រេឌីតចាំបាច់សម្រាប់ទទួលនូវការលើកកម្ពស់គុណវុឌ្ឍិ និងផលប្រយោជន៍បន្ថែម | ២០១៩-២០២០ | នា.បវ<br>គ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន |
| | ៨.២ | សមាហរណកម្មរាល់សកម្មភាពការងារវិក្រឹតការទាំងអស់ដែលរៀបចំដោយក្រសួងអប់រំ យុវជន និងកីឡា ម្ចាស់ជំនួយ និងអង្គការក្រៅរដ្ឋាភិបាលដោយប្រើប្រាស់ប្រព័ន្ធក្រេឌីត និងប្រព័ន្ធទិន្នន័យតាមដានការងារវិក្រឹតការ | ២០១៩-២០២០ | នា.បវ<br>គ្រឹះស្ថានបណ្តុះបណ្តាល<br>គ្រូបង្រៀន |
| ៩. ប្រព័ន្ធគាំទ្រនាយកសាលារៀន | ៩.១ | បណ្តុះបណ្តាលនាយកសាលា | ២០១៩ | វិទ្យាស្ថានជាតិអប់រំ |
| | ៩.២ | បង្កើតសមាគមនាយកសាលារៀន | ២០១៩-២០២០ | នា.នីតិកម្ម<br>នា.បវ<br>នា.បល |
| | ៩.៣ | អនុវត្តស្តង់ដានាយកសាលា | រៀងរាល់ឆ្នាំ | នា.បវ<br>នា.បល |
| | ៩.៤ | អនុវត្តសៀវភៅណែនាំការគ្រប់គ្រងសាលារៀន | រៀងរាល់ឆ្នាំ | នា.បវ<br>នា.បល<br>គ្រឹះស្ថានសិក្សា |

## ៤. សន្និដ្ឋាន

ជោគជ័យ នៃការអនុវត្តក្របខណ្ឌនេះ រួមចំណែកការអភិវឌ្ឍមូលធនមនុស្សដែលជាកម្លាំងពលកម្មសកម្ម និងមានផលិតភាពសេដ្ឋកិច្ចខ្ពស់ ធានានូវការអភិវឌ្ឍប្រកបដោយចីរភាព។ក្រសួងអប់រំ យុវជន និងកីឡា សង្ឃឹមយ៉ាងមុតមាំថា ភាគីពាក់ព័ន្ធទាំងអស់នឹងចូលរួមអនុវត្តក្របខណ្ឌគន្លងអាជីពគ្រូបង្រៀនដើម្បីជាប្រយោជន៍ដល់ការអភិវឌ្ឍប្រកបដោយចីរភាព។

# សន្ទានុក្រម

- **គន្លងអាជីពគ្រូបង្រៀន**

  ក្របខណ្ឌសម្រាប់គាំទ្រ និងលើកទឹកចិត្តគ្រូបង្រៀន គណៈគ្រប់គ្រងសាលារៀន និងអ្នកឯកទេសអប់រំ ឱ្យបំពេញការងារឱ្យអស់សក្តានុពលរបស់ខ្លួន ដើម្បីធានាឱ្យសិស្សទទួលបានគុណសម្បទាតាមភូមិសិក្សានីមួយៗ ដូចមានចែងក្នុងក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅ និងអប់រំបច្ចេកទេស។

- **លក្ខខណ្ឌតម្រូវ**

  លក្ខខណ្ឌដែលមានលក្ខណៈជាកាតព្វកិច្ច ដើម្បីទទួលបានងារវិជ្ជាជីវៈនៅក្នុងគន្លងអាជីពគ្រូបង្រៀនបាន។

- **លក្ខខណ្ឌជម្រើស**

  លក្ខខណ្ឌដែលអាចមានក៏បាន មិនមានក៏បាន។ គ្រូបង្រៀន គណៈគ្រប់គ្រង និងអ្នកឯកទេសដែលបំពេញលក្ខខណ្ឌនេះនឹងទទួលបានពិន្ទុបន្ថែម។

- **ចំណេះដឹងវិទ្យាសាស្ត្រ**

  សំដៅលើការយកវិទ្យាសាស្ត្រជាមូលដ្ឋាននៃការបណ្តុះបណ្តាលធនធានមនុស្ស តាមរយៈការលើកកម្ពស់ការស្រាវជ្រាវនៅគ្រប់កម្រិត និងការអភិវឌ្ឍសមត្ថភាពជំនាញវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា។

- **ការស្រាវជ្រាវ**

  ជាការអង្កេតជាប្រព័ន្ធលើបញ្ហាណាមួយដើម្បីរកដំណោះស្រាយប្រកបដោយវិទ្យាសាស្ត្រ។ ការស្រាវជ្រាវអាចស្ថិតក្នុងកម្រិតផ្សេងៗ ដូចជាកម្រិតថ្នាក់រៀនដែលហៅថា ការស្រាវជ្រាវប្រតិបត្តិប្រើសម្រាប់ដោះស្រាយបញ្ហាសិស្សរៀនខ្សោយកម្រិតសាលារៀន ឬការស្រាវជ្រាវកម្រិតខ្ពស់សម្រាប់បង្កើតទ្រឹស្តី ឬវិធីសាស្ត្រអ្វីមួយ។

- **ក្រេឌីត**

  ជាឯកតា ឬ តម្លៃដែលយកជាខ្នាតសម្រាប់វាស់វែងពីលទ្ធផលសិក្សាសម្រេចបាននៅក្នុងសញ្ញាណម៉ោងនៃកម្រិតគុណវុឌ្ឍិដែលបានផ្តល់។ ជាតម្លៃដែលផ្តល់សម្រាប់ការសិក្សាដែលសម្រេចបាន និងត្រូវបានផ្ទៀងផ្ទាត់តាមរយៈការវាយតម្លៃត្រឹមត្រូវ និងជឿទុកចិត្តបាន។

- **ចរិយាសម្បត្តិសកល**

  សំដៅលើការកសាងឥរិយាបថគោរពវិន័យការងារ ឬ អាជីព ការសម្រេចសមិទ្ធកម្ម ឬស្នាដៃ និងការទទួលយកទស្សនៈថ្មីៗ ដោយសម្របបានទៅនឹងការប្រែប្រួលជានិច្ចនៃបរិការណ៍សកល និងទិដ្ឋភាពខុសគ្នានៃវប្បធម៌ចម្រុះជាតិសាសន៍។

- **គុណសម្បទា**

  កញ្ចប់សមត្ថភាពដែលគ្រូបង្រៀន ឬគណៈគ្រប់គ្រងសាលារៀន ឬ អ្នកឯកទេសអប់រំ ត្រូវមានសម្រាប់ធានាប្រសិទ្ធភាពនៃការបង្រៀន និងការដឹកនាំដើម្បីសម្រេចលទ្ធផលសិក្សារំពឹងទុករបស់សិស្ស។ គុណសម្បទាក៏ជាកញ្ចប់សមត្ថភាពដែលសិស្សត្រូវទទួលបានក្រោយពេលបញ្ចប់ភូមិសិក្សានីមួយៗ ដែលរួមាន វិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា។